# ទំនៀមសែនដូនតាក្នុងរដូវភ្ជុំបិណ្ឌ

ពាក្យថា "ភ្ជុំបិណ្ឌ" ឬ "ប្រភពពិធីបុណ្យភ្ជុំបិណ្ឌ" ពុំលើកមកនិយាយរៀបរាប់ក្នុងអត្ថបទនេះទេ។ បំណងក្នុងអត្ថបទនេះ ខ្ញុំចង់រៀបរាប់បង្ហាញទិដ្ឋភាពតូចមួយនៃទំនៀមសែនដូនតា និងបណ្តែតដូនតា ជាកិច្ចចុងបំផុតនៃពិធីបុណ្យភ្ជុំបិណ្ឌ។ នៅតំបន់ខ្លះក្នុងល្ងាចថ្ងៃ១៥ រោច ខែភទ្របទ នៃថ្ងៃទី២ក្នុងពិធីបុណ្យភ្ជុំបិណ្ឌ ដោយក្នុងគ្រួសារនីមួយៗតែងតែរៀបចំកិច្ចសែនដូនតា។ តាមការសង្កេត សមាជិកគ្រួសារដែលទៅរស់នៅ ឬចេញទៅរកស៊ីជិតឆ្ងាយក្តី តែងវិលត្រឡប់មកជួបជុំក្នុងឱកាសសែនដូនតាពុំដែលខាន។ ប៉ុន្តែទំនៀមសែនដូនតានេះគេមើលឃើញថា ពុំប្រតិបត្តិដូចគ្នាទូទៅពីស្រុកមួយទៅស្រុកមួយឡើយ តែក៏មានប្រតិបត្តិជាហូរហែក្នុងសហគមន៍ខ្មែរនៅកម្ពុជាក្រោមដែរ។[1] បើធៀបនឹងទំនៀមក្នុងព្រះបរមរាជវាំង ហាក់ដូចជាត្រូវនឹងព្រះរាជពិធីថ្វាយព្រះបិតរ។[2]

តាមទម្លាប់ក្នុងវេលាល្ងាចនោះ គេត្រូវមានគ្រឿងសំណែនដូចជា ផ្លែឈើ ចេកទុំ នំចំណី ស្រា មាន់ស្ងោ ទឹកក្រូច បង្អែម ចម្អាប ព្រមទាំងបាយបិណ្ឌ-បាយបត្តបូរ រៀបចំដាក់លើកម្រាលក្នុងទីសមគួរមួយ។ សំណែនក្នុងកិច្ចនេះក៏ពុំដូចគ្នាទាំងស្រុងដែរ ខ្លះថែមទាំងមានរៀបដូងខ្ចី១គូ សំពត់អាវថ្មី និងគ្រឿងក្រអូបជាដើម។ លុះរៀបចំស្រេចហើយគេអញ្ជើញចាស់ទុំ និងញាតិមិត្តភូមិផងរបងជាមួយមកចូលរួម។ បន្ទាប់មកចាស់ទុំណាម្នាក់ ឬមេគ្រួសារផ្តើមអុជទៀនធូបព្រេនបីបទ ក្នុងន័យសូមអញ្ជើញជីដូនជីតាដែលចែកឋានទៅ ចូលមកសេពសោយទទួលយកម្ហូបចំណីកូនចៅរៀបចំជូនក្នុងឱកាសនេះ។ ពេលព្រេនចប់មួយបទ គេប្រួចស្រាបន្តិចទៅក្នុងចានសំណែនដោយឡែកមួយដែលមានដាក់លាយច្របល់គ្នាទាំងនំចំណី បង្អែម ចម្អាប ផ្លែឈើ និងជាពិសេសគួរឱ្យសម្គាល់ គេតែងកាត់ក្បាលមាន់ស្ងោមកដាក់ចូលផង។ សំណែនមួយចាននេះ គេដាក់នៅចុងជាយកន្ទេលផុតពីសំណែននានា។ លុះព្រេនចប់ គេច្រើនយកសំណែននេះ ទៅចាក់ក្រោមជណ្តើរផ្ទះ ឬនៅជាយភូមិដែលគេយល់ថា សម្រាប់ពពួកអមនុស្សផ្សេងៗពុំមែនជាញាតិ។[3] ចំពោះ

---

[1] លឹម ថេងហាក់ ២០០៩

[2] ចាប ពិន ១៩៦០: ៨៦ និង ពេជ្រ សល់ ១៩៦៦: ៤៧-៤៩

[3] ពេលខ្លះគេហៅពពួកអមនុស្សទាំងនោះថា "ពួកដោយពោយ"។

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

ពាក្យនិយាយ (ឬសូត្រ?) ទាំងបីបទហាក់ដូចជាពោលចេញមកតែរៀងខ្លួន ពុំមានពាក្យតែមួយដូចធម៌អាថ៌ ឬអ្វីដែលមានការតាក់តែងចងក្រងច្បាស់លាស់ឡើយ តែមានខ្លឹមសាររួមជាការអញ្ជើញជីដូនជីតា ឬញាតិទាំងប្រាំពីរសន្តានដែលស្លាប់ទៅ មកទទួលសំណែនដែលរៀបចំក្នុងឱកាសនេះឱ្យបានបរិបូណ៌។

លុះព្រលឹមថ្ងៃ១ កើត ត្រូវនឹងខែអស្សុជ គេរៀបចំជូនដូនតាត្រឡប់ទៅស្រុកវិញ។[៤] រណ្ដាប់ដែលគេតែងរៀបចំដាក់ជូនដំណើររួមមាន នំចំណី ផ្លែឈើ គ្រាប់ពោត គ្រាប់សណ្ដែក ល្ង អង្ករ អំបិល ម្រេច ខ្ទឹម ។ល។ ខ្ចប់ជាកញ្ចប់តូចៗដូចគ្រឿងបម្រុង ដាក់លើស្រទបចេកបត់ឱ្យមានសណ្ឋានដូចទូក ឬសង្កឹក ឬក្បូនសម្រាប់ផ្ទុករណ្ដាប់ទាំងនោះ។[៥] បន្ទាប់មក គេអុជទៀនធូបដោតដាក់ក្នុងទូកនោះ បណ្ដែតតាមទឹក ហើយឧបកិច្ចថា "ទៅស្រុកទន្លេស្ងួតកន្ទួតមួយដើម" ដែលជាស្រុកមាននិយាយក្នុងរឿងព្រេងពាក់ព័ន្ធនឹងពិធីបុណ្យភ្ជុំបិណ្ឌ។ ក្នុងវេលានេះដែរ គេក៏មានកិច្ចសូមខមាទោសគោ-ក្របី ជាពាហនៈអូសទាញយ៉ាងសំខាន់ ដោយយកទៅលាងទឹក លាបប្រេង ចងអំបោះ ឱ្យស៊ីចេក និងនំ ហើយនិយាយសូមខមាទោស ដែលខ្លួនជាម្ចាស់ធ្លាប់វាយដំដេរប្រទេច ដឹកជញ្ជូនធ្ងន់ស្រាលក្នុងការងារស្រែចម្ការកន្លងមក។ ពេញមួយថ្ងៃនេះ គេពុំប្រើសត្វទាំងនោះឡើយ បើទោះជាការងារស្រែចម្ការពុំទាន់រួចរាល់ចប់សព្វគ្រប់ក្ដី។ កិច្ចសែនព្រេនចុងបំផុតនៃពិធីភ្ជុំបិណ្ឌនេះ ក៏ឃើញក្នុងជំនឿជនជាតិកួយក្នុងស្រុកវាលវែង ខេត្តកំពង់ធំដែរ ដែលជាក្រុមជនជាតិដើមភាគតិចមានជំនាញខ្ពស់ខាងផលិតដែក។ គេតែងរៀបចំចំណីម្ហូបអាហារបង្អែម ចម្អាប គ្រឿងភេសជ្ជៈ សែនដែក (ឧបករណ៍ដែក ឬមានដែកខាងក្នុង) ដែលគេធ្លាប់ប្រើប្រាស់ប្រចាំថ្ងៃដូចជា កាំបិត ពូថៅ ដឹង រណា ចប និងជំនីក នៅក្នុងថ្ងៃ១៤ រោច ហើយគេតមមិនយកឧបករណ៍ទាំងនោះមកប្រើឡើយ រង់ចាំរហូតផុតថ្ងៃភ្ជុំ។[៦]

---

[៤] ម៉ែន ប្រាង និង អាំ ឆន ១៩៩៤: ៤៦

[៥] Ang Chouléan 1986: 93-95

[៦] គង់ វីរៈ "ពិធីសែនដែករបស់ជនជាតិកួយនៅភូមិវាលវែង" https://www.yosothor.org/publications/khmer-renaissance/chapter-two/phity-sen-dek-rbos-jun-jeat-kouy-nov-phumi-veal-veng.html

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

# បញ្ជីរូបភាព





រូបលេខ១ និងលេខ២ សំណែន និងគ្រឿងវណ្ដាប់រៀបចំក្នុងកិច្ចសែនដូនតា



រូបលេខ៣ សំណែន និងរូបថតបុព្វការីដែលចែកឋាន ដាក់រៀបចំឧទ្ទិសក្នុងកិច្ចសែនដូនតា



រូបលេខ៤ កិច្ចសែនដូនតាគ្រួសារនីមួយៗ



រូបលេខ៥ រណ្ដាប់ផ្សេងៗដែលវេចខ្ចប់ដាក់ក្នុងទូកស្រទបចេកបណ្ដែតជូនដូនតា



រូបលេខ៦ ទូកស្រទបចេកបណ្ដែតជូនដូនតា



រូបលេខ៧ រណ្ដាប់សូមខមាទោសគោ-ក្របី

# ឯកសារយោង

គង់ វីរៈ "ពិធីសែនដែករបស់ជនជាតិកួយនៅភូមិវាលវែង" បណ្ដាញព័ត៌មានវប្បធម៌ខ្មែរ
https://www.yosothor.org/publications/khmer-renaissance/chapter-two/phity-sen-dek-rbos-jun-jeat-kouy-nov-phumi-veal-veng.html

ចាប ពិន

១៩៦០. *ព្រះរាជពិធីទ្វាទសមាស ភាគ៣,* ពុទ្ធសាសនបណ្ឌិត្យ, ភ្នំពេញ

ពេជ្រ សល់

១៩៦៦. *ពិធីប្រចាំដប់ពីរខែ,* ពុទ្ធសាសនបណ្ឌិត្យ, ភ្នំពេញ

ម៉ែន ប្រាង និង អាំ ឆន

១៩៩៤. "បុណ្យភ្ជុំបិណ្ឌ", *កម្ពុជសុរិយា,* ឆ្នាំទី៤៨ លេខ២ ខែមេសា-ឧសភា-មិថុនា ពុទ្ធសាសនបណ្ឌិត្យ, ភ្នំពេញ, ទំ.៤៥-៥៥

លឹម ថេងហាក់

២០០៩. *ប្រពៃណីបុណ្យសែនដូនតាខ្មែរនៅកម្ពុជាក្រោម,* សារណាបញ្ចប់បរិញ្ញាបត្រ, មហាវិទ្យាល័យបុរាណវិទ្យា នៃសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ, ភ្នំពេញ

Ang Chouléan

1986. *Les êtres surnaturels dans la religion Populaire khmère,* Cedoreck, Paris

អរិយធម៌ខ្មែរ KHMER CIVILIZATION